**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** ២៧ **អយក.** សគារ

# សេចក្តីណែនាំ
## ស្តីពី
## ការស្នើសុំអាជ្ញាប័ណ្ណអប់រំបើកគ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន

កន្លងមកក្រសួងអប់រំ យុវជន និងកីឡាសង្កេតឃើញថា គ្រឹះស្ថានសិក្សាចំណេះទូទៅឯកជនភាគច្រើនបានបង្កើត ឬបើកដំណើរការស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ទន្ទឹមនេះ នៅមានគ្រឹះស្ថានសិក្សាចំណេះទូទៅឯកជនមួយចំនួនតូច បានបើកដំណើរការដោយគ្មានអាជ្ញាប័ណ្ណ ឬការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡាឡើយ។

ដើម្បីពង្រឹងការអនុវត្តច្បាប់ស្តីពីការអប់រំ និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងៗទៀត សំដៅរួមចំណែកធ្វើឱ្យសម្រេចគោលនយោបាយកំណែទម្រង់របស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ការចូលរួមរបស់វិស័យឯកជន ពិសេសដើម្បីពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈវិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡា សូមណែនាំដល់ម្ចាស់គ្រឹះស្ថានសិក្សាចំណេះទូទៅឯកជនដូចខាងក្រោម៖

១.គ្រប់គ្រឹះស្ថានសិក្សាចំណេះទូទៅឯកជនត្រូវមានអាជ្ញាប័ណ្ណអប់រំ ឬលិខិតអនុញ្ញាតដែលចេញដោយក្រសួងអប់រំ យុវជន និងកីឡា ឬក្រុង ស្រុក ខណ្ឌគោលដៅនៃការិយាល័យច្រកចេញចូលតែមួយ មុននឹងបើកដំណើរការផ្តល់សេវាអប់រំ។

២.គ្រឹះស្ថានសិក្សាចំណេះទូទៅឯកជនដែលមិនទាន់បានបំពេញគ្រប់លក្ខខណ្ឌតម្រូវស្តីពីការស្នើសុំអាជ្ញាប័ណ្ណអប់រំសម្រាប់បង្កើត ឬដំណើរការគ្រឹះស្ថានសិក្សា និងថ្នាក់បណ្តុះបណ្តាលត្រូវស្នើសុំអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ឬក្រុង ស្រុក ខណ្ឌនៃការិយាល័យច្រកចេញចូលតែមួយ ក្នុងរយៈពេលយ៉ាងយូរ ៤៥(សែសិបប្រាំ)ថ្ងៃ ក្រោយពីសេចក្តីណែនាំនេះចេញជាធរមាន។

ចំពោះសាលា ឬថ្នាក់មត្តេយ្យសិក្សាឯកជនកម្មវិធីជាតិ និងអន្តរជាតិ ថ្នាក់បណ្តុះបណ្តាលជំនាញ និងភាសាបរទេសវគ្គខ្លីៗតិចជាង១ឆ្នាំ និងអាជ្ញាប័ណ្ណក្លឹបហាត់ប្រាណ ត្រូវស្នើសុំអាជ្ញាប័ណ្ណអប់រំនៅក្រុង ស្រុក ខណ្ឌ គោលដៅនៃការិយាល័យច្រកចេញចូលតែមួយ។

ចំពោះការស្នើសុំអាជ្ញាប័ណ្ណទទួលស្គាល់គ្រឹះស្ថានសិក្សាដែលមានតែមួយភូមិសិក្សា ឬច្រើនភូមិសិក្សាបញ្ចូលគ្នា (ទារកដ្ឋាននិងមត្តេយ្យសិក្សា មត្តេយ្យសិក្សានិងបឋមសិក្សា ពីមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សា ពីបឋមសិក្សារហូតដល់មធ្យមសិក្សា ) ត្រូវស្នើសុំអាជ្ញាប័ណ្ណនៅច្រកចេញចូល



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ /២១៧ ២៥៣ /៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

តែមួយនៃក្រសួងអប់រំ យុវជន និងកីឡាដែលមានទីតាំងអគារលេខ ៨០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ។

៣.ផុតរយៈពេលនៃការកំណត់ខាងលើនេះ ក្រសួងអប់រំ យុវជន និងកីឡា នឹងចាត់វិធានការដូចមានចែងក្នុងច្បាប់ស្តីពី ការអប់រំ ត្រង់មាត្រា៨៦ ដែលបានកំណត់ថា អំពើបង្កើត ឬបើកឱ្យដំណើរការនូវគ្រឹះស្ថានសិក្សា និងថ្នាក់បណ្តុះបណ្តាលដោយគ្មានអាជ្ញាប័ណ្ណអប់រំជាមុន ដូចមានបញ្ញត្តិនៅក្នុងមាត្រា១១នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី២,០០០,០០០.០០ (ពីរលាន) រៀល ទៅ ១០,០០០,០០០.០០ (ដប់លាន) រៀល។ ក្នុងករណីមិនរាងចាលត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ខាងលើ។

៤- នាយកដ្ឋានជំនាញ និងគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវផ្សព្វផ្សាយ អនុវត្ត ពិនិត្យតាមដាន និងធ្វើរបាយការណ៍ជូនច្រកចេញចូលតែមួយ ដើម្បីបូកសរុបរបាយការណ៍ជូនក្រសួងអប់រំ យុវជន និងកីឡា។

ទទួលបានសេចក្តីណែនាំនេះ នាយកដ្ឋានជំនាញ អង្គភាពពាក់ព័ន្ធ និងគ្រឹះស្ថានសិក្សាចំណេះទូទៅឯកជនទាំងអស់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ [illegible] ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន

**កន្លែងទទួល ៖**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យក្រសួងអប់រំ យុវជន និងកីឡា
- គ្រប់អង្គភាពក្រោមឱវាទទីស្តីការក្រសួងអ.យ.ក

*«ដើម្បីជូនជ្រាប»*

- សាលារាជធានី-ខេត្ត
- មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត

*«ដើម្បីសហការ»*

- ច្រកចេញចូលតែមួយនៃក្រសួងអប់រំ យុវជន និងកីឡា
- ក្រុង ស្រុក ខណ្ឌគោលដៅនៃការិយាល័យច្រកចេញចូលតែមួយ
- គ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន

*«ដើម្បីអនុវត្ត»*

- ឯកសារ កាលប្បវត្តិ៖ នា.នីតិកម្ម